ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៨ ស.ស.រ.

**សេចក្តីសម្រេច**

**ស្តីពី**

**ការកំណត់របៀបរបបការងារ និង ការបែងចែកភារកិច្ច**

**របស់រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

****+****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ ១ :** កំណត់របៀបរបបការងារ និង បែងចែកភារកិច្ច ជូនរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចតទៅ ÷

១- ឯកឧត្តម **ឃួ សិទ្ធី:** ទទួលបន្ទុកជានាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ។

២- ឯកឧត្តម **សុខ ចិន្តាសោភា:** ទទួលបន្ទុកជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៣- ឯកឧត្តម **ម៉ម សារិន:** ទទួលបន្ទុកសម្របសម្រួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយនឹងអង្គការនីតិបញ្ញត្តិ ។

៤- ឯកឧត្តម **ស្រ៊ី ថាមរុន្ទ:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងការសម្របសម្រួលកិច្ចការទំនាក់ទំនងអន្តរជាតិ ។

៥- ឯកឧត្តម **ទៅ សុវណ្ណ:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋ-មន្ត្រី ក្នុងការតាមដានសម្របសម្រួលកិច្ចការយុត្តិធម៌ ។

៦- ឯកឧត្តម **ឈៀង យ៉ាណារ៉ា:** ទទួលបន្ទុកជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ជាអគ្គលេខាធិការនៃគណកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា ។

៧- ឯកឧត្តម **ឌុល ស៊ឿន:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងការតាមដានសម្របសម្រួលកិច្ចការមហាផ្ទៃ ។

៨- ឯកឧត្តម **យូ ស៊ុនឡុង:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងការតាមដានសម្របសម្រួលកិច្ចការមុខងារសាធារណៈ ។

៩- ឯកឧត្តម **អូស្មាន ហាសាន់:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយក-រដ្ឋមន្ត្រី ក្នុងការតាមដានសម្របសម្រួលកិច្ចការទីផ្សារការងារ និង សម្របសម្រួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយនឹងសហគមន៍អ៊ីស្លាម ។

១០- ឯកឧត្តម **សោម ស៊ឿន:** ទទួលបន្ទុកសម្របសម្រួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយនឹងបណ្តាគណៈបក្សនយោបាយ និង អង្គការសង្គមស៊ីវិល ។

១១- ឯកឧត្តម **សុខ គន្ធរ:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងការតាមដានសម្របសម្រួលកិច្ចការសហគ្រាសធុនតូច និងមធ្យម និង មីក្រូហិរញ្ញវត្ថុ។

១២- ឯកឧត្តម **ហ្សកគរីយ៉ា អាដាម:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងកិច្ចការសាសនា ។

១៣- ឯកឧត្តម **កៅ គីមហួន:** ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយក-រដ្ឋមន្ត្រី ក្នុងការតាមដានសម្របសម្រួលកិច្ចការបរទេស និង អាស៊ាន ។

**ប្រការ ២ :** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៣ :** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ១ រូបៗ មានជំនួយការ ៤ រូប ក្នុងនោះ ១ រូប មានឋានៈស្មើអគ្គនាយក, ១ រូប មានឋានៈស្មើអគ្គនាយករង និង ២ រូប មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ៨ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១ និង ប្រការ ៥*
- *ឯកសារ- កាលប្បវត្តិ*